ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៚៛៚

លេខៈ ៣៨៧

ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០១ **នាមនាមប្រជារាស្ត្រខ្មែរ**

សាលដីកា **តុលាការកំពូល**

លេខៈ ៤៥ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៤

ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២-លោក ប្រាក់ គឹមសាន ជាចៅក្រម

៣-លោក ជីវ កេង ជាចៅក្រមរបាយការណ៍

៤-លោក យស់ សូខឿន ជាចៅក្រម

៥-លោក ប៉ែន សារឿន ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី **គួច ចន្ថា**

តំណាងមហាអយ្យការ

លោក **សាយ សាវី** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៤៨ "គ" ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១២០ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍រវាងៈ

ដើមចោទឈ្មោះ **ចេង ចឿង** (ជាចុងបណ្តឹងសាទុក្ខ) អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅភូមិក្រេស ឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។

មានមេធាវីលោក ហួត សោភ័ណ្ឌ ។

ចុងចំលើយឈ្មោះ **ប៉ែន ណាន** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៩៥ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។

តតីយជនឈ្មោះ សៅ គីម (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរ

លក់ដូរ ទីលំនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។

តតិយជនឈ្មោះ សៅ កែម (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅ ភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។

មានមេធាវី លោក មៀច សំអាន់ ។

**<u>កម្មវត្ថុបណ្តឹង</u>** : ប្តឹងសុំឱ្យរុះរើផ្ទះចេញពីដី

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៨២ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០១របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣១៧ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ របស់លោកមៀច សំអាន់ ជាមេធាវីការពារឱ្យតតិយជន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៤៨"គ" ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៥-០៩-១៩៩៧ របស់ដើមចោទឈ្មោះ បេង មឿន ប្តឹងឱ្យចុងចម្លើយ ឈ្មោះ ប៉ែន ណន និងក្រុមគ្រួសាររុះរើផ្ទះ ចេញពីដីរបស់ខ្លួន ដោយសំអាងថា ដីស្រែមួយកន្លែងនោះខ្លួន គ្រប់គ្រងកាន់កាប់តាំងពីឆ្នាំ១៩៧៩ ជាប់រហូតមក ខ្លួនមានប័ណ្ណសំគាល់សិទ្ធិលេខ B1-០០៦១ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩២ ទៀតផង ។

នៅឆ្នាំ១៩៩៣ ខ្លួនបានលក់ដីស្រែនោះឱ្យឈ្មោះ ថន សាគុន នៅឆ្នាំ១៩៩៦ លោក ថន សាគុន បានទាមទារយកមាសពីខ្លួនវិញ ដោយសារចុងចម្លើយ និងក្រុមគ្រួសារទៅរស់នៅលើដីនោះ ។

បានឃើញដីកាសំរេចតាមពាក្យសុំលេខ ១១៧២/៩៩ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ១៩៩៩ របស់ តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះបេងមឿន ចុះថ្ងៃទី១២-៧-១៩៩៩ ទុកជាត្រឹមត្រូវតាម ទំរង់ និងគតិច្បាប់ ។

២-សំរេចឱ្យឈ្មោះបេង មឿន ថែរក្សាកាន់កាប់ និងធ្វើស្រែលើដីដែលកំពុងមានទំនាស់ ស្ថិតនៅភូមិគោកត្នោត ឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលមានព្រំប្រទល់ខាងជើងទល់ នឹងផ្លូវចូលវត្ត ខាងត្បូងទល់នឹងរបងតិត ខាងកើតទល់នឹងលៀម លី និងខាងលិចទល់នឹងផ្លូវរទេះជាបណ្តោះ- អាសន្នសិន រង់ចាំតុលាការសំរេចដល់អង្គសេចក្តី ។

៣-ក្នុងការអនុវត្តដីកានេះ បើភាគីណាមួយមិនសុខចិត្ត មានសិទ្ធិប្តឹងទៅតុលាការខេត្ត សៀមរាប-ឧត្តរមានជ័យ ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹងពីដីកានេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៩៩ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៨ របស់តុលាការខេត្ត

សៀមរាប-ឧត្តរមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធបណ្តឹងសុំសិទ្ធិគ្រប់គ្រងដីមួយកន្លែង កំពុងមានទំនាស់របស់ចុងចម្លើយឈ្មោះ អ្នកស្រីប៉ែន ណន ចោលដោយខុសនឹងគតិច្បាប់ ។

៣-សំរេចឱ្យចុងចម្លើយឈ្មោះអ្នកស្រី ប៉ែន ណន និង ក្រុមគ្រួសាររុះរើផ្ទះចេញពីលើដី មួយកន្លែងកំពុងមានទំនាស់ដែលមានបណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខបេ១-00៦១ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩២ ស្ថិតនៅភូមិគោកត្នោត ឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។

៤-សំរេចឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វីង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ បូករួម ៧.០០០៛ ។ ប្រាក់នេះ បាន កាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់អោយ ចុងចម្លើយសងប្រាក់ ៧.០០០៛ នេះ ទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ ៥០.០០០៛ បន្ថែមទៀត ដែលត្រូវដាក់ថវិការដ្ឋ ៤០.០០០រៀល និងរង្វាន់ក្រឡាបញ្ជីក្នុងកម្ពុជា១០.០០០រៀល ។ ពន្ធសមាមាត្រនេះ ត្រូវឱ្យដើមចោទបង់មុនដែរ ទើបបង្គាប់ឱ្យចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

៥-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍កំណត់ពីរខែ គិត ពីថ្ងៃនេះតទៅ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២000 របស់តុលាការខេត្ត សៀមរាប-ឧត្តរមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធបណ្តឹងតបសុំសិទ្ធិគ្រប់គ្រងដីមួយកន្លែងកំពុងមានទំនាស់របស់ចុងចម្លើយឈ្មោះ អ្នកស្រី ប៉ែន ណន ចោលដោយខុសនឹងគតិច្បាប់ ។

៣-ទទួលពាក្យបណ្តឹងរបស់អ្នកស្រី សៅ គីម សុំបញ្ចូលជាតតិយជន សុំបដិសេធ សាលក្រម សុំផ្អាកការអនុវត្តសាលក្រម និងសុំសិទ្ធិគ្រប់គ្រងដីមួយប្លង់ទំហំ២០ម៉ែត្រ គុណនឹង៤០ម៉ែត្រ ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

៤-ទទួលពាក្យបណ្តឹងរបស់អ្នកស្រី សៅ កែម សុំបញ្ចូលជាតតិយជន សុំបដិសេធ សាលក្រម សុំផ្អាកការអនុវត្តសាលក្រម និងសុំសិទ្ធិគ្រប់គ្រងដីមួយប្លង់ ទំហំ ២០ម៉ែត្រ គុណនឹង៤០ម៉ែត្រ ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

៥-ទទួលស្គាល់ដីមួយកន្លែង ដែលមានបណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ

បេ១-០០៦១ ចុះថ្ងៃទី១២-៣-១៩៩២ ជាកម្មសិទ្ធិស្របច្បាប់របស់ដើមចោទឈ្មោះ បេង មឿន ។ ប្រគល់ដីមានទំនាស់ទំហំ ១.៦០០ម៉ែត្រការេ ដែលមានទីតាំងស្ថិតនៅក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ បេ១-០០៦១ ចុះថ្ងៃទី១២-៣-១៩៩២ ឱ្យឈ្មោះបេង មឿន ជាម្ចាស់កម្មសិទ្ធិ ។

៦-សំរេចឱ្យចុងចម្លើយឈ្មោះអ្នកស្រី ប៉ែន ណន ១. អ្នកស្រី សៅ គីម ១. អ្នកស្រី សៅ កែម ១. ព្រមទាំងក្រុមគ្រួសាររុះរើផ្ទះចេញពីរង្វង់ដី ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ បេ១-០០៦១ ចុះថ្ងៃទី១២-៣-១៩៩២ ។

៧-សំរេចឱ្យអ្នកស្រីសៅ គីម សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១.០០០.០០០៛ "មួយលានរៀល" ឱ្យទៅដើមចោទឈ្មោះ បេង មឿន ។ សុំលើសពីនេះ លើកចោល ។

៨-សំរេចឱ្យអ្នកស្រីសៅ កែម សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១.០០០.០០០៛ " មួយលានរៀល" ឱ្យទៅដើមចោទឈ្មោះ បេង មឿន ។ សុំលើសពីនេះ លើកចោល ។

៩-សំរេចឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ បូករួម ៧.០០០៛ ។ ប្រាក់នេះ បានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់អោយចុងចម្លើយសងប្រាក់ ៧.០០០៛ នេះ ទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ ៧០.០០០៛ បន្ថែមទៀតដែលត្រូវដាក់ថវិការដ្ឋ ៥៦.០០០រៀល និងរង្វាន់ក្រឡាបញ្ជីក្នុងកម្ពុជា១៤.០០០រៀល ។ ពន្ធសមាមាត្រនេះត្រូវឱ្យដើមចោទបង់មុនដែរ ទើបបង្គាប់ឱ្យចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

៩-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើភាគីណាមួយមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៣ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រី សៅ កែម ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០០ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រី សៅ គីម ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០០ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៦ "គ" ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧-១០-២០០០ របស់ឈ្មោះសៅ គីម ,សៅ កែម

ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោល ដោយទាស់ខុសនឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី០៥-៩-២០០០ របស់តុលាការខេត្តសៀមរាប ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និងលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០រៀល ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខបេង មឿន "ចុងបណ្តឹងឧទ្ធរណ៍ " កំបាំងមុខឈ្មោះ សៅ គីម , សៅ កែម ជាដើមបណ្តឹងឧទ្ធរណ៍ និងមេធាវី បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ២៥ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០១ របស់លោក មៀច សំអ៊ាន់ ជាមេធាវីការពារឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៦"គ" ចុះថ្ងៃទី១៥ខែឧសភា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៨ "គ" ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងចុះថ្ងៃទី២៩-៥-២០០១ របស់ឈ្មោះមៀច សំអ៊ាន់ ជាមេធាវីតំណាងឱ្យតតិយជន ចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ២៦"គ" ចុះថ្ងៃទី ១៧-០៥-២០០១ របស់សាលាឧទ្ធរណ៍ ដោយកែតម្រូវសាលក្រមតុលាការខេត្តសៀមរាបលេខ ១២១ ចុះថ្ងៃទី០៥-៩-២០០០ ត្រង់ចំណុចទី៧ និងទី៨ ស្តីពីសំណងជំងឺចិត្ត ត្រូវលើកចោល ចំណុចក្រៅពីនេះ រក្សាទុកដដែល ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣១៧ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ របស់លោកមៀច សំអ៊ាន់ ជាមេធាវីការពារឱ្យតតិយជន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៤៨"គ" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១ របស់ឈ្មោះ សៅ គីម និង សៅ កែម។

បានឃើញសារណាឆ្លើយតបចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២ របស់ឈ្មោះ បេង មឿន ។

បានឃើញសារណាបន្ថែមចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះមៀច សំអ៊ាន់ ជាមេធាវី

ការពារឱ្យតតិយជនឈ្មោះ សៅ គីម និង សៅ កែម ។

បានឃើញសារណាបន្ថែមចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះ មៀច សំអ៊ាន់ ជាមេធាវីការពារឱ្យតតិយជនឈ្មោះសៅ គីម និង សៅ កែម ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា

- បណ្តឹងសាទុក្ខរបស់មេធាវីតតិយជន ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

- សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ទាំងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់តតិយជនឈ្មោះ សៅ គីម នាពេលជំនុំជំរះថា : បានជាខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល មកពីតុលាការខេត្ត និងសាលាឧទ្ធរណ៍កាត់ក្តីមិនត្រឹមត្រូវឱ្យខ្លួន ព្រោះថា ដីទំនាស់នេះម្តាយរបស់ខ្លួន គាត់ទិញពីយោធា ដែលមានទំហំ៤០ម៉ែត្រ ៤ជ្រុង ចំនួន២កន្លែង មួយប្លង់មានទំហំ៤០ម x២០ម ចំនួនពីរឡូពីលោកជាញ់ សារុធ និងកូនឈ្មោះរុធ អូន ហើយម្តាយខ្លួនបានផ្ទេរឈ្មោះមកខ្លួនឈ្មោះសៅគីម និងប្អូនឈ្មោះសៅ កែម ជាអ្នកគ្រប់គ្រងបន្តពីម្តាយខ្លួន ។ ហេតុនេះ ខ្លួនសុំឱ្យតុលាការកំពូលកាត់ក្តីប្រគល់ដីនេះមកឱ្យខ្លួនរស់នៅវិញ ព្រោះខ្លួនមានដីតែមួយកន្លែងនេះទេ និង សុំឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

បានស្តាប់ចំលើយរបស់ឈ្មោះបេង មឿង នាពេលជំនុំជំរះថា :ដីទំនាស់នេះ ខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ហើយធ្វើស្រែនៅលើដីនោះបានពីរ បី រដូវ ទើបកងទ័ពវៀតណាមទៅបោះទីតាំងលើដីទួលស្ថិតនៅក្នុងរង្វង់ដីរបស់ខ្លួន ។ ខ្លួននៅតែកាន់កាប់ដីនោះរហូត បន្ទាប់ពីកងទ័ពវៀតណាមដកចេញនៅឆ្នាំ១៩៨៨-១៩៨៩ ហើយនៅឆ្នាំ១៩៩២ ខ្លួនបានដាក់ពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី ត្រឹមត្រូវតាមច្បាប់ ។ នៅឆ្នាំ១៩៩៣ ខ្លួនលក់ដីនេះឱ្យទៅលោក ថង សាគុណ តម្លៃ៧តំលឹងមាស តែពុំបានកាត់ឈ្មោះទេ ខ្លួនប្រគល់ប័ណ្ណកម្មសិទ្ធិជូនគាត់ ។ នៅឆ្នាំ១៩៩៦ លោក ថង សាគុណ ហៅខ្លួនទៅប្រាប់ឱ្យដេញអ្នកទៅនៅលើដីនោះ បើដេញមិនចេញ គាត់យកលុយវិញ ។ ពេលនោះ ខ្លួនប្តឹងរដ្ឋអំណាចឱ្យជួយដោះស្រាយជាមួយអ្នកស្រី ប៉ែន ណន ដែលរំលោភចូលមកតាំងទីលំនៅលើដីរបស់ខ្លួននៅចុងឆ្នាំ១៩៩៣ កាលនោះសៅ គីម ទើបតែមានអាយុ១៧ឆ្នាំ និងសៅ កែម អាយុ៥ឆ្នាំទេ ។ តុលាការខេត្តសៀមរាប បានសំរេចសេចក្តីឱ្យខ្លួនឈ្នះ ហើយសាលក្រមស្ថាពរហើយ ទើប សៅ គីម, សៅ កែម ប្តឹងចូលជាតតិយជន ហេតុនេះ សូមលោកតុលាការកំពូលមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក មៀច សំអ៊ាន់ ជាមេធាវីការពារឱ្យតតិយជន បានលើកឡើង

បញ្ជាក់ថា :ដីទំនាស់នេះ កាលដើមឡើយ គឺព្រៃស្បាត គ្មានមនុស្សរស់នៅ និងគ្មានស្រែចំការអ្វីនៅទីនោះទេ ការលើកឡើងរបស់ឈ្មោះបេង មឿង គឺមិនមែនជាការពិតទេ ហើយខ្លួនសូមជំទាស់ និងរបាយការណ៍របស់ចៅក្រមទាំងស្រុង ព្រោះថា លោក បេង មឿង គាត់រស់នៅក្នុងភូមិគោកត្នោត ឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ហើយដីទំនាស់ស្ថិតនៅក្នុងភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ហេតុដូច្នេះ គាត់ឆ្លើយពុំបានច្បាស់លាស់អំពីផែនដីរដ្ឋបាលទេ ។ ហើយដីទំនាស់នេះ អ្នកស្រី ប៉ែន ណន បានទិញពីយោធា ហើយគាត់មានសិទ្ធិបែងចែកទ្រព្យមរតកនេះឱ្យទៅកូនរបស់គាត់ត្រឹមត្រូវតាមច្បាប់ហើយ ហើយសុំឱ្យតុលាការមេត្តាពិចារណា . អំពីកំណត់ហេតុរបស់ក្រសួងការពារជាតិ ដែលនាយកដ្ឋានអធិការកិច្ចចុះទៅអង្កេតលើគំនូសប្លង់ដីរបស់យោធិនរំសាយ ដែលក្រសួងការពារជាតិធ្វើការបែងចែកឱ្យយោធាមាន ៥៧២ប្លង់ និង ៥៧២គ្រួសារ ដីទាំងអស់នេះ ត្រូវបានប្រជាជនប្តឹងទៅក្រសួងការពារជាតិ ។

ខ្លួនសុំសំណូមពរឱ្យតុលាការកំពូលសំរេចបដិសេធសាលក្រមរបស់តុលាការខេត្ត និងសាលដីការបស់សាលាឧទ្ធរណ៍ចោលទាំងស្រុង ។ ហើយសុំបង្វិលសំណុំរឿងក្តីនេះ ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ហួត សោភ័ណ្ឌ ជាមេធាវីការពារឱ្យដើមចោទបានលើកឡើងថា : ដីទំនាស់នេះ កូនក្តីខ្លួន បានកាន់កាប់តាំងពីឆ្នាំ ១៩៧៩ រហូតមក ក្រោយមកកងទ័ពវៀតណាមបោះទីតាំងនៅក្នុងរង្វង់ដីរបស់គាត់ កូនក្តីខ្លួននៅតែកាន់កាប់រហូតពេលដែលកងទ័ពវៀតណាមដកចេញ ។ នៅឆ្នាំ១៩៩២ កូនក្តីខ្លួនបានធ្វើប័ណ្ណកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់ ។ ហើយខ្លួនសុំបដិសេធរាល់ការលើកឡើងរបស់មេធាវីតតិយជន ពុំមានភាពត្រឹមត្រូវឡើយ ពីព្រោះ អ្នកស្រីប៉ែន ណន បានមករំលោភយកដីរបស់កូនក្តីខ្លួន ហើយកូនក្តីខ្លួនបានដាក់ពាក្យប្តឹងទៅតុលាការខេត្តសៀមរាប តុលាការខេត្តសៀមរាប បានសំរេចឱ្យកូនក្តីខ្លួនឈ្នះក្តីរហូតសាលក្រមចូលស្ថាពរ អនុវត្តចប់សព្វគ្រប់ហើយ ទើបតតិយជនមកប្តឹងឧទ្ធរណ៍ ហេតុដូច្នេះ ការប្តឹងទាមទារចូលជាតតិយជននេះ គឺពុំត្រឹមត្រូវទេ អ្នកស្រី ប៉ែន ណន គ្មានសិទ្ធិផ្ទេរទ្រព្យមរតកអ្នកដទៃឱ្យទៅកូនរបស់អ្នកស្រីបានឡើយ ពីព្រោះពុំមែនទ្រព្យផ្ទាល់ខ្លួនរបស់អ្នកស្រីឡើយ ។

ខ្លួនសូមសំណូមពរ សុំឱ្យក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និង សំរេចតំកល់សាលក្រមរបស់តុលាការខេត្តសៀមរាប និងសាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។ សុំឱ្យតុលាការកំពូលមេត្តាផ្តល់ភាពយុត្តិធម៌ឱ្យកូនក្តីខ្លួនផង ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចំលើយអ្នកស្រីសៅ គីម ចម្លើយលោក បេង មឿន និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី.

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣១៧ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០១ របស់លោក មៀច សំអ៊ាន់ ជាមេធាវីតតិយជន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលអ្នកស្រី សៅ គីម និង អ្នកស្រី សៅ កែម និង មេធាវីរបស់អ្នកស្រី លើកឡើងនៅក្នុងសារណាជាបន្តបន្ទាប់ថា ដីទំនាស់នេះ នៅឆ្នាំ១៩៨១ គណៈកម្មាធិការប្រជាជនទីរួមខេត្ត បានប្រគល់ឱ្យយោធាខេត្តសៀមរាប ហើយចាប់ពីពេលនោះមក យោធាខេត្តបានគ្រប់គ្រងរហូតដល់ឆ្នាំ១៩៩២ ទើបគណៈកម្មាធិការប្រជាជនទីរួមខេត្តវាស់ដីចែកឱ្យប្រជាជន ប្រជាជនមាតុភូមិនិវត្តសំរាប់សាងសង់លំនៅ-ដ្ឋាន ហើយម្តាយអ្នកស្រីបានប្រគល់ដីនេះឱ្យអ្នកស្រី ធ្វើឱ្យអ្នកស្រីមានសិទ្ធិលើដីទំនាស់តាមច្បាប់ភូមិបាល និង តាមអនុក្រឹត្យលេខ ២៥អនក្រ ចុះថ្ងៃទី២២-៤-១៩៨៩ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា :

- តាមចម្លើយរបស់អ្នកស្រី ប៉ែន ណន ចម្លើយរបស់អ្នកស្រីសៅ គីម,អ្នកស្រីសៅ កែម លោក ដាញ់ សាវុធ និងអ្នកស្រី វុធដា សុទ្ធតែឆ្លើយបញ្ជាក់ដូចៗគ្នាថា ដីទំនាស់នេះ យោធាបានបែងចែក ឱ្យលោកដាញ់ សាវុធ និងកូនឈ្មោះវុធ អួន រួចបានលក់ឱ្យអ្នកស្រីប៉ែន ណន ជាម្តាយអ្នកស្រី សៅ គីម និងអ្នកស្រី សៅ កែម ។

- យល់ឃើញថា ដើមចោទបានប្តឹងពីអ្នកស្រីប៉ែនណន ហើយតុលាការខេត្តសៀមរាបក៏បានសំរេច សេចក្តីជាស្ថាពរ តាមសាលក្រមរដ្ឋប្បវេណីលេខ៩៩ ចុះថ្ងៃទី២៨-១០-១៩៩៨ ប្រគល់ដីទំនាស់ឱ្យដើមចោទ និងបានអនុវត្តចប់សព្វគ្រប់ហើយ ។ ដូច្នេះតតិយជនឈ្មោះសៅ គីម និង សៅ កែម ដែលទទួលស្គាល់ថា ម្តាយខ្លួនបានបែងចែកដីទំនាស់ឱ្យខ្លួននោះ ពុំមានគុណសម្បត្តិតាំងខ្លួនជាតតិយជនមកប្តឹងទាមទារដីទំនាស់ នេះជាថ្មីទៀតបានទេ ពីព្រោះតាមសៀវភៅស្នាក់នៅចុះថ្ងៃទី០៥-៦-១៩៩៩ នៅឆ្នាំ១៩៩២ តតិយជនទាំងពីរ នាក់នេះ គឺឈ្មោះសៅ គីម ទើបមានអាយុ១៧ឆ្នាំ ហើយឈ្មោះសៅ កែម ទើបមានអាយុ៥ឆ្នាំប៉ុណ្ណោះ ហើយសុទ្ធតែស្ថិតនៅក្នុងបន្ទុកអ្នកស្រី ប៉ែន ណន និងប្តីជាមេគ្រួសារទាំងអស់ ។

- យល់ឃើញថា តាមគំនូសប្លង់ទីតាំងរួមរបស់ឃោធាខេត្តសៀមរាប ចុះថ្ងៃទី២០-០៦-១៩៩៥ ដីរបស់ឈ្មោះដាញ់ សារុធ ពុំស្ថិតនៅលើដីទំនាស់នេះទេ គឺស្ថិតនៅលើប្លង់លេខ ៩៩ និង ១១៩ ។ ហើយតាមលិខិតប្រគល់ដីរបស់ឃោធាខេត្តឱ្យអ្នកស្រីសៅ កែម និង អ្នកស្រី សៅ គីម គឺមានស្នាមកោសលប់ កែ ឈ្មោះអ្នកនៅជាប់ព្រំប្រទល់មែន ។

- យល់ឃើញថា គូភាគីសុទ្ធតែមានសំអាងជាសាក្សី ជាអាជ្ញាធរ និងមន្ត្រីជំនាញដូចៗគ្នា បញ្ជាក់អំពីសិទ្ធិលើដីទំនាស់នេះ ជូនមកតុលាការ ប៉ុន្តែ តុលាការកំពូលពិនិត្យលើគុណសម្បត្តិរបស់ឈ្មោះសៅ គីម និងឈ្មោះសៅ កែម អ្នកស្រីពុំអាចតាំងខ្លួនជាតតីយជន ដើម្បីសុំមោឃៈភាពសាលក្រមស្ថាពរលេខ ៩៩ ចុះថ្ងៃទី២៨-១០-១៩៩៨ របស់តុលាការខេត្តសៀមរាបបានទេ ។

- យល់ឃើញថា ការដែលលោកមេធាវីតតីយជនលើកឡើងពេលសវនាការនេះថាអ្នកស្រីប៉ែនណានមានសិទ្ធិផ្ទេរជាមរតកឱ្យទៅកូន ហើយកូនមានសិទ្ធិប្តឹងចូលជាតតីយជនបាននោះជាការពុំត្រឹមត្រូវទេ ពីព្រោះការផ្ទេរសិទ្ធិនេះ អាចផ្ទេរបានតែលើទ្រព្យសម្បត្តិរបស់ខ្លួនប៉ុណ្ណោះ ប៉ុន្តែ តាមពិតដីទំនាស់នេះ ជាកម្មសិទ្ធិរបស់ដើមចោទ ដែលមានបណ្ណសំគាល់សិទ្ធិរួចទៅហើយ ហើយម្តាយរបស់តតីយជនក៏បានយល់ព្រមរុះរើផ្ទះចេញពីដីទំនាស់តាមសាលក្រមស្ថាពររបស់តុលាការខេត្តរួចទៅហើយ ។ ដូច្នេះ ដីទំនាស់នេះ មិនអាចក្លាយជាមរតកសំរាប់តតីយជនបានទេ ។

- យល់ឃើញថា តតីយជនឈ្មោះ សៅ កែម បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤៨"គ" ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ និងតតីយជនឈ្មោះសៅ គីម**

**កំបាំងមុខតតីយជនឈ្មោះសៅ កែម ប៉ុន្តែ ចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ ៣១៧ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ របស់លោកមៀច សំអាន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ៤៨ "គ" ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀលដែលលោក បេង មឿន បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្គីងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវអោយតតីយជន សងប្រាក់១៩.០០០៛ នេះ ទៅលោក បេង មឿន វិញ .

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០០៤ ។